# ការប្រឡងសរសេរអត្ថបទ(Writing Essay Exams)

ដើម្បីត្រៀមខ្លួនប្រឡងសរសេរតែងសេចក្តី អ្នកត្រូវតែធ្វើកិច្ចការយ៉ាងច្រើនលើសពីការទន្ទេញឲ្យចាំនូវការពិតមួយចំនួន។ អ្នកត្រូវតែសំយោគពត៌មាននិងត្រូវរៀបចំគំនិតទាំងឡាយឲ្យក្លាយទៅជាវាក្យខ័ណ្ឌនិងអត្ថបទមានលក្ខណៈច្បាស់លាស់ មានលំដាប់លំដោយត្រឹមត្រូវ។

## រៀបចំផែនការឆ្លើយទៅនឹងការប្រឡងការសរសេរអត្ថបទ

*(១) ត្រូវគិតទៅដល់អ្នកអាននិងគោលបំណងរបស់អ្នក*

អ្នកអានទីមួយនៃរាល់អត្ថបទប្រឡងគឺគ្រូបង្រៀនដែលរៀបចំកិច្ចការប្រឡងនោះ។ ពេលអ្នកអានសំណួរទាំងនោះរួចអ្នកត្រូវគិតថាតើគ្រូបង្រៀនអ្នកបានសង្កត់ធ្ងន់លើចំណុចណាកាលពីនៅក្នុងថ្នាក់។ អ្នកត្រូវចងចាំថាគោលបំណងរបស់អ្នកគឺត្រូវបង្ហាញថាអ្នកយល់ច្បាស់អត្ថបទសិក្សា ដោយមិនត្រូវធ្វើកំណត់សម្គាល់ប្លែកណាមួយឬបញ្ចូលពត៌មានដែលមិនទាក់ទងចូលក្នុងអត្ថបទនោះទេ។ ត្រូវខំប្រឹងស្វែងរករាល់ពាក្យពេចន៍ជាក់លាក់ដែលប្រើក្នុងវិស័យសិក្សានិមួយៗហើយអ្នកត្រូវតែប្រើប្រាស់ក្បួនច្បាប់នៃការសរសេរដែលគ្រូបង្រៀនអ្នកបានពិភាក្សានៅក្នុងថ្នាក់រៀន។

*(២) ចូរអានឲ្យបានចប់ចុងចប់ដើមនូវអត្ថបទប្រឡង*

មុនពេលចាប់ផ្តើមសរសេរ ចូរអ្នកអានអត្ថបទប្រឡងទាំងមូលដោយយកចិត្តទុកដាក់បំផុតដើម្បីកំណត់រកមើលថាអ្វីជាអាទិភាពសម្រាប់អ្នកធ្វើមុនគេនិងតើត្រូវប្រើយុទ្ធសាស្ត្របែបណា។ មុនដំបូងអ្នកត្រូវប្រាកដថាអត្ថបទប្រឡងរបស់អ្នកមានត្រឹមត្រូវសព្វគ្រប់ ហើយអ្នកយល់ច្បាស់ថាតើសំណួរនិមួយៗចង់សួរពីអ្វី។ បើអ្នកត្រូវការការពន្យល់បន្ថែម ចូរសួរគ្រូបង្រៀនអ្នកឬអ្នកកាន់ការពេលនោះឲ្យជួយពន្យល់បាន។ បន្ទាប់មកចូររៀបចំផែនការសរសេរឲ្យបានច្បាស់លាស់ ចូរសម្រេចចិត្តថាតើអ្នកត្រូវការពេលវេលាប៉ុន្មានក្នុងរាល់សំណួរនិមួយៗ។ ជាទូទៅពិន្ទុនៃសំណួរនិមួយៗឬចំនួនសំណួរអាចឲ្យអ្នកសម្រេចចិត្តបានថាតើអ្នកគួរចំណាយពេលប៉ុន្មានក្នុងរាល់សំណួរទាំងនោះ។ ជាឧទាហរណ៍ បើសិនជាអត្ថបទប្រឡងនោះមានតម្លៃស្មើនឹង៥០ពិន្ទុក្នុង១០០ពិន្ទុ អ្នកប្រហែលជាត្រូវចំណាយពេលពាក់កណ្តាលនៃពេលវេលាទាំងអស់ដើម្បីរៀបចំផែនការ ចាប់សរសេរ និងកែកំហុសនៅក្នុងចំឡើយនោះ។

បន្ទាប់មកអ្នកត្រូវសម្រេចចិត្តថាតើត្រូវចាប់ផ្តើមពីទីណា។ យុទ្ធសាស្ត្រដ៏ល្អគឺដំបូងចូរចាប់ឆ្លើយសំណួរខ្លីៗ(ឬឆ្លើយសំណួរណាដែលអ្នកយល់ច្បាស់)។ គន្លឹះមួយនេះជួយអ្នកឲ្យគេចផុតពីការចំណាយពេលលើសំណួរដែលធ្វើឲ្យអ្នកទាល់គំនិតនាំឲ្យអ្នកសល់ពេលតិចតួចដើម្បីសរសេរចម្លើយដ៏ល្អចំពោះសំណួរដែលអ្នកយល់ច្បាស់។ លើសពីនោះទៅទៀតចូរអ្នកចាប់ផ្តើមជាមួយនឹងសំណួរដែលធ្វើឲ្យអ្នកមានការទុកចិត្តលើខ្លួនឯង។

*(៣) ចូរអានរាល់សំណួរដោយប្រុងប្រយ័ត្ន*

ដើម្បីឆ្លើយសំណួរមួយឲ្យបានល្អអ្នកត្រូវតែយល់សំណួរជាមុន។ ក្នុងពេលអ្នកអានសំណួរប្រឡងសរសេរអត្ថបទ អ្នកអាចគូសបន្ទាត់ពីក្រោមពាក្យគន្លឹះសំខាន់ៗ។

*ឧទាហរណ៍៖*

**សង្គមវិទ្យា:** Distinguish among Social Darwinism, instinct theory, and sociobiology, giving example of each.

**តូរតន្ត្រី:** Explain how Milton Babbitt used the computer to expand Schoenberg's twelve-tone method.

**ទស្សនៈវិទ្យា:** Define existentialism and identify three influential existentialist works, explaining why they are important.

ចូរពិនិត្យឲ្យបានច្បាស់រាល់ពាក្យដែលគេប្រើនៅក្នុងសំណួរ។ ប្រសិនបើសំណួរសុំឲ្យអ្នក compare and contrast នូវរបៀបគ្រប់គ្រងពីរយ៉ាង ក៏ប៉ុន្តែអ្នកបែរជាសរសេរដោយធ្វើការពណ៌នា(description)ឬវិភាគ(analysis)របៀបគ្រប់គ្រងមួយវិញ វាមិនអាចទទួលយកបានទេបើទោះបីជាអ្នកសរសេរបានល្អក្បោះក្បាយយ៉ាងណាក៏ដោយ។ បើសំណួរសុំឲ្យអ្នកនិយាយពីហេតុនិងផល ប៉ុន្តែអ្នកបែរជាធ្វើការពិភាក្សាអំពីមូលហេតុតែមួយមុខ នោះក៏មិនអាចទទួលយកបានដែរ។

*ពាក្យគន្លឹះនៅក្នុងសំណួរប្រឡង*

| | | |
|---|---|---|
| ចូរពន្យល់ (Explain) | ចូរបញ្ជាក់ឲ្យច្បាស់ (Clarify) | ចូរធ្វើការចាត់ថ្នាក់ (Classify) |
| ចូរប្រៀបធៀប (Compare) | ចូរជំណាលប្រាប់ (Relate) | ចូររកឲ្យឃើញ (Identify) |
| ចូររកភាពខុសគ្នា (Contrast) | ចូរនិយាយដោះសារ (Justify) | ចូរធ្វើការអធិប្បាយលម្អិត (Illustrate) |
| ចូររ៉ាយរ៉ាប់ (Trace) | ចូរវិភាគ (Analyze) | ចូរពន្យល់អត្ថន័យ (Define) |
| ចូរវាយតម្លៃ (Evaluate) | ចូរសង្ខេប (Summarize) | ចូរផ្តល់គំនិតគាំទ្រ (Support) |
| ចូរពិភាក្សា (Discuss) | ចូរពិពណ៌នា (Describe) | ចូរបកស្រាយ (Interpret) |

*(៤) ចូរស្វះស្វែងរុករកគំនិត*

នៅពេលអ្នកយល់ច្បាស់សំណួរហើយ ចូរចាប់ផ្តើមស្វះស្វែងរុករកគំនិតដោយកត់ត្រាទុករាល់គំនិតពាក់ព័ន្ធដែលអ្នកនៅចងចាំ។ បន្ទាប់មក ចូរកំណត់ថាតើគំនិតណាមួយដែលមានប្រយោជន៍បំផុតរួចហើយលប់ចោលគំនិតដែលមិនសូវមានទំនាក់ទំនង។ ចូរអ្នកឧស្សាហ៍ក្រឡេក មើលសំណួរប្រឡងនិងរាល់គំនិតគាំទ្ររបស់អ្នកដើម្បីជួយអ្នកឲ្យឈានទៅដល់ការបង្កើតបានគោលគំនិតសម្រាប់សម្រាប់ ការសរសេរ របស់អ្នក។

## ការបង្កើតគោលគំនិតនិងគម្រោងនៃការសរសេរ

អ្នកអាចសរសេរសំណួរប្រឡងឡើងវិញដោយប្រើភាសាសាមញ្ញដែលអ្នកងាយយល់ក្រោមរូបភាពជាសេចក្តីប្រកាសអំពីគោលគំនិត (Thesis statement)។ ឧទាហរណ៍ សំណួរអំពីប្រវត្តិសាស្ត្រសហរដ្ឋអាមេរិកដែលសួរថា"Give a detailed summary of the effects of the Great Depression on the United States, briefly discussing the major causes of the economic collapse (ចូរអ្នកផ្តល់ការសង្ខេបមួយអំពីផលប៉ះពាល់នៃឱនភាពសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរទៅលើសហរដ្ឋអាមេរិកដោយធ្វើការពិភាក្សាខ្លីៗលើមូលហេតុចម្បងៗរបស់ការធ្លាក់ចុះនៃសេដ្ឋកិច្ចផងដែរ)"គឺអ្នកអាចសរសេរសេចក្តីប្រកាសអំពីគោលគំនិតបានដូចខាងក្រោម៖

> The Great Depression, caused by the American government's economic policies, had major political, economic, and social effects on the United States.

ដោយសារពេលវេលាមានកំណត់ ចូរព្រាងគម្រោងសរសេរដោយកត់ត្រារាល់គំនិតចម្បងៗនិងគំនិតគាំទ្រទាំងឡាយដោយតំរៀបវាទៅតាមលំដាប់ដែលអ្នកមានផែនការសរសេរអំពីវា។ ចូរត្រួតពិនិត្យគម្រោងសរសេររបស់អ្នកដោយផ្ទឹមវាជាមួយនឹងសំណួរប្រឡងដើម្បីធានាឲ្យប្រាកដថាគម្រោងនោះមានគ្រប់ចំណុចដែលសំណួរចង់បាន។